# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ព្រះរាជសុន្ទរកថា
## របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
## នៅក្នុងកិច្ចប្រជុំមេដឹកនាំនៃសន្និសីទលើកទី២១ របស់អនុសញ្ញាក្របខ័ណ្ឌ
## សហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ

*ថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៥*

- **ឯកឧត្តមប្រធានាធិបតីនៃសាធារណរដ្ឋបារាំង**
- **ឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិ**
- **ឯកឧត្តម លោកជំទាវជាប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីមេត្រី!**

ជាបឋម ខ្ញុំសូមសំដែងសមានទុក្ខដ៏ជ្រាលជ្រៅចំពោះគ្រួសារ និងមិត្តភក្តិរបស់ជនរងគ្រោះនៅក្នុងការវាយប្រហារភេរវកម្មនៅក្នុងទីក្រុងប៉ារីស និងជាមួយប្រជាជនបារាំង ក្នុងកាលៈទេសៈដ៏លំបាក។ ខ្ញុំសូមអះអាងចំពោះមុខឯកឧត្តមប្រធានាធិបតីថា កម្ពុជាគាំទ្របារាំងយ៉ាងម៉ឺងម៉ាត់នៅក្នុងការប្រយុទ្ធប្រឆាំងនឹងជនដែលប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ឃោរឃៅទាំងនេះ។

**ឯកឧត្តមប្រធានាធិបតី ឯកឧត្តម លោកជំទាវប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល លោក លោកស្រីជាទីមេត្រី!**

ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមកំណត់នៃសម័យកាលយើងនេះ ហើយយើងបានចាប់ផ្តើមទទួលឥទ្ធិពលរបស់វារួចមកហើយក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ។ វិស័យសំខាន់ៗនៃការអភិវឌ្ឍមនុស្ស ដូចជា កសិកម្ម សន្តិសុខស្បៀង ការផ្គត់ផ្គង់ទឹក សុខាភិបាល ចំណាកស្រុក និងភាពក្រីក្រ

កំពុងប្រឈមនឹងការគំរាមកំហែងធំៗពីការប្រែប្រួលអាកាសធាតុ។ គោលដៅអភិវឌ្ឍន៍ដោយចីរភាពទាំងដប់ប្រាំពីរ ដែលសម័យប្រជុំពេញអង្គនៃអង្គការសហប្រជាជាតិបានអនុម័តក្នុងពេលថ្មីៗនេះ ក៏អាចរងការប៉ះពាល់ផងដែរពីការប្រែប្រួលអាកាសធាតុ។

នៅពេលដែលយើងកំពុងជួបគ្នាពិភាក្សានេះ កសិករកម្ពុជាកំពុងពុះពារប្រឈមនឹងការប្រែប្រួលរបបទឹកភ្លៀងប្រចាំរដូវ និងគ្រោះរាំងស្ងួតរយៈពេលវែង ដែលប៉ះពាល់ដល់ផលិតកម្មកសិកម្ម និងសន្តិសុខស្បៀង។ គ្រោះមហន្តរាយធម្មជាតិបានកើតឡើងកាន់តែញឹកញាប់ និងខ្លាំងក្លាជាងមុនជាលំដាប់។ ទឹកជំនន់ឆ្នាំ២០១៣ នៅកម្ពុជា បានធ្វើឲ្យប្រទេសយើងខ្ញុំបាត់បង់២% នៃផលិតផលក្នុងស្រុកសរុប ដោយមានប្រជាជនជិត៣៨០.០០០គ្រួសារ នៅក្នុងខេត្តចំនួន ២០ ក្នុងចំណោមខេត្ត-ក្រុងសរុបចំនួន២៥ រងផលប៉ះពាល់ និងបានធ្វើឱ្យមនុស្ស១៦៨នាក់បាត់បង់ជីវិត ដែលក្នុងនោះភាគច្រើនជាកុមារ។

ក្នុងឋានៈជាតំណាងនៃប្រទេសកំពុងអភិវឌ្ឍន៍មួយ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គោលការណ៍យុត្តិធម៌នឹងស្ថិតនៅជាស្នូលនៃការចរចាក្នុងរយៈពេលពីរសប្តាហ៍ខាងមុខនេះ។ ដូចប្រទេសដទៃជាច្រើនទៀតដែលមានតំណាងនៅក្នុងបន្ទប់នេះផងដែរ កម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលសំខាន់បំផុតមួយនៃការអភិវឌ្ឍរបស់ខ្លួន។ យើងត្រូវដោះស្រាយក្នុងពេលជាមួយគ្នានូវបញ្ហាភាពក្រីក្រ ជម្រុញកំណើនសេដ្ឋកិច្ចអភិវឌ្ឍឧស្សាហកម្ម លើកស្ទួយគុណភាពធនធានមនុស្សនិងសេវាសង្គម ធានាសន្តិសុខថាមពល ហើយជាមួយគ្នានោះ រក្សានូវភាពប្រកួតប្រជែងនៅក្នុងបរិយាកាសបើកចំហទាំងថ្នាក់តំបន់ និងពិភពលោក។ នៅក្នុងបរិការណ៍នៃរបៀបវារៈកំណែទម្រង់នេះ កម្ពុជាមានគោលដៅច្បាស់លាស់ក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ដូចមានចែងនៅក្នុងឯកសាររបាយការណ៍នៃការចូលរួមចំណែករបស់កម្ពុជាក្នុងការអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុរបស់យើង។

ភាគចំណែកនៃធនធានសាធារណៈរបស់យើង សម្រាប់ចំណាយឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ កាន់តែកើនឡើងជាលំដាប់។ នេះសឱ្យឃើញពីការប្តេជ្ញាចិត្តកម្រិតខ្ពស់របស់យើង ពិតមែនតែកម្រិតនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់កម្ពុជាមកទល់បច្ចុប្បន្ននេះ មានតិចតួចស្តួចស្តើងក្តី។ ក៏ប៉ុន្តែយើងមិនអាចសម្រេចបានគោលដៅប្រកបដោយមហិច្ឆិតាទាំងនេះតែឯងបានឡើយ។

ធនធានហិរញ្ញវត្ថុ និងការផ្ទេរបច្ចេកវិទ្យា គឺជាតម្រូវការចាំបាច់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីធ្វើសកម្មភាពបានពេញលេញនៅក្នុងការឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ ហើយខ្ញុំសង្ឃឹមថាកិច្ចព្រមព្រៀងក្រុងប៉ារីសនឹងដាក់បញ្ចូលការប្តេជ្ញាមោះមុតសម្រាប់កិច្ចការទាំងនេះ។ ការផ្តល់ហិរញ្ញវត្ថុក្នុងដំណាក់កាលដំបូងទៅក្នុងមូលនិធិអាកាសធាតុបៃតង គឺជាសញ្ញាវិជ្ជមានប្រកបដោយការលើកទឹកចិត្ត។

យើងត្រូវតែរក្សា និងបង្កើនបន្ថែមទៀតនូវនិន្នាការនេះ នៅក្នុងរយៈពេលខាងមុខ ហើយចាំបាច់ត្រូវបង្កើនការផ្តល់ធនធានដល់យន្តការហិរញ្ញប្បទានដទៃទៀត ដូចជាមូលនិធិសម្រាប់ប្រទេសអភិវឌ្ឍន៍តិចតួច ជាដើម។ យន្តការសមស្របនានាផ្សេងទៀតក៏នឹងមានសារៈសំខាន់ជាសារវន្តផងដែរ ដើម្បីជម្រុញ

ការស្រាវជ្រាវ និងការវិនិយោគឯកជនក្នុងវិស័យថាមពលកកើតឡើងវិញ ប្រសិទ្ធភាពថាមពល កិច្ចការពារព្រៃឈើ ហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ និងបច្ចេកវិទ្យាបន្សុំនានា។

**ឯកឧត្តមប្រធានាធិបតី ឯកឧត្តម លោកជំទាវប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាល លោក លោកស្រីជាទីមេត្រី!**

ការចរចាអាកាសធាតុកន្លងមកបានអូសបន្លាយអស់រយៈពេលច្រើនជាងម្ភៃឆ្នាំហើយ។ នៅក្នុងអំឡុងពេលនេះ យើងបានទទួលភស្តុតាងជាក់លាក់អំពីការប្រែប្រួលអាកាសធាតុ និងចំណងទាក់ទងជាមួយសកម្មភាពមនុស្ស។ យើងក៏បានជួបប្រទះផងដែរនូវផលប៉ះពាល់ដំបូងៗនៃការប្រែប្រួលអាកាសធាតុ ហើយការគាំទ្រពីប្រជាជនទូទៅឱ្យមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងការសម្របសម្រួលនៅទូទាំងពិភពលោក ក៏បាននិងកំពុងកើនឡើងផងដែរ។ ប្រទេសភាគច្រើនដែលមានតំណាងនៅទីនេះបានធ្វើការសន្យារួចមកហើយ ថានឹងខិតខំរួមចំណែកដោះស្រាយបញ្ហានេះ។ ប៉ុន្តែយើងដឹងថា ការសន្យាទាំងនេះនៅពុំទាន់គ្រប់គ្រាន់នៅឡើយទេ។ វិភាគទានដំបូងទាំងនេះនឹងមិនអាចទប់ស្កាត់ការឡើងកម្តៅផែនដីឱ្យនៅក្រោមកម្រិត២°C បានឡើយ។ ក្នុងនាមជាមេដឹកនាំ យើងមានកាតព្វកិច្ចទទួលខុសត្រូវក្នុងការទំលាយភាពទ័លច្រកនេះ។ យើងមានភស្តុតាង យើងមានដំណោះស្រាយ ហើយយើងដឹងថា យើងអាចដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដោយជាមួយគ្នានោះបង្វែរសង្គមរបស់យើងឆ្ពោះទៅលំនាំនៃការអភិវឌ្ឍដោយចីរភាព។ ដូច្នេះ យើងមិនអាច និងមិនគួរបន្សល់ទុកបញ្ហានេះសម្រាប់ឱ្យកូនចៅយើងជំនាន់ក្រោយដោះស្រាយនោះទេ។ យើងត្រូវតែសម្រេចឱ្យបាននូវដំណោះស្រាយនៅទីនេះ និងនៅក្នុងពេលនេះ។

ការប្រែប្រួលអាកាសធាតុ គឺជាធាតុដ៏សំខាន់មួយនៃរបៀបវារៈឆ្នាំ២០៣០ ស្តីពីការអភិវឌ្ឍដោយចីរភាព ហើយការប្រជុំរបស់យើងនៅទីនេះក្នុងទីក្រុងប៉ារីស ត្រូវតែនាំឆ្ពោះទៅរកកិច្ចព្រមព្រៀងជាប្រវត្តិសាស្ត្រលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយប្រទេសជឿនលឿន និងប្រទេសឧស្សាហកម្ម ក្នុងនោះប្រទេសអភិវឌ្ឍន៍តិចតួចអាចចូលរួមដោយស្ម័គ្រចិត្តផងដែរ ក្រោមជំនួយហិរញ្ញវត្ថុ និងការផ្ទេរបច្ចេកវិទ្យា។

ខ្ញុំសូមអំពាវនាវថា យើងត្រូវធ្វើការសម្រេចនៅថ្ងៃនេះក្នុងភាពជាអ្នកដឹកនាំដែលមានការទទួលខុសត្រូវ តបតាមការរំពឹងទុកដ៏ស្របច្បាប់របស់ប្រជាជនរបស់យើង និងមនុស្សជំនាន់ក្រោយៗទៀត។

**សូមអរគុណ!**